**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករទូរគមនាគមន៍កម្ពុជា**

លេខ :...០២៩៧........ន.ទ.ក.

# សេចក្តីណែនាំ

# ស្តីពី

# ដំណើរការចូលរួមអនុវត្តផែនការការពារសុវត្ថិភាពសន្តិសុខជាតិ គម្រោងទី៣

អនុលោមតាមផែនការអនុវត្តគម្រោងទី៣ ពាក់ព័ន្ធនឹងដំណើរការចូលរួមអនុវត្តផែនការការពារសុវត្ថិភាពសន្តិសុខជាតិ របស់អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ដើម្បីធានាប្រសិទ្ធភាពលើកិច្ចការពារសន្តិសុខជាតិរបស់រាជរដ្ឋាភិបាលជូនសាធារណជន និយ័តករទូរគមនាគមន៍កម្ពុជា សូមធ្វើការណែនាំដល់ប្រតិបត្តិករទូរគមនាគមន៍ចល័តទាំងអស់ ត្រូវអនុវត្តការងារ និងបំពេញកាតព្វកិច្ចឱ្យម៉ឺងម៉ាត់ ដូចខាងក្រោម៖

១) ត្រៀមលក្ខណៈសម្បត្តិឱ្យរួចជាស្រេច ចូលរួមសហការជាមួយអ្នកបច្ចេកទេសរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ពេលចុះទៅបំពេញបេសកកម្មការងារនៅតាមទីតាំងរបស់ខ្លួន នាពេលខាងមុខ ។

២) ត្រៀមរៀបចំទិន្នន័យពាក់ព័ន្ធនឹងលក្ខណៈបច្ចេកទេសឱ្យហើយ ពាក់ព័ន្ធនឹងរាល់ការតភ្ជាប់រវាងប្រព័ន្ធរបស់ខ្លួន ជាមួយនឹងឧបករណ៍បច្ចេកវិទ្យាប្រព័ន្ធគ្រប់គ្រងស៊ើបអង្កេត និងវិភាគទិន្នន័យ OMNIX-First Mile VoLTE និង VoWiFi LI គម្រោងទី៣ បន្ថែមទៅលើប្រព័ន្ធតាមដានទូរស័ព្ទដៃ RELEANT Monitoring Center ដែលមានសមត្ថភាពក្នុងការស្រាវជ្រាវចាប់បទល្មើសតាមប្រព័ន្ធអ៊ីនធឺណិត ពីទូរស័ព្ទដៃគម្រោងទី២ ដោយដំណើរការក្នុងពេលតែមួយ និងប្រព័ន្ធកាមេរ៉ាតាមដានស្វែងរកមុខសញ្ញា របស់អគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ។

៣) ត្រៀមខ្លួនជាមុនឱ្យរួចជាស្រេចនូវរាល់ផែនការគ្រោងថវិការបស់ខ្លួន សម្រាប់រាល់ការរៀបចំបំពាក់ឧបករណ៍ពាក់ព័ន្ធនឹងកិច្ចការពារសុវត្ថិភាពសន្តិសុខជាតិ ក្នុងបរិបទនៃការវិវត្តិនិងនវានុវត្តន៍នៃបច្ចេកវិទ្យាថ្មីៗតម្រូវ នាពេលអនាគត។

ក្រោយពីទទួលបានសេចក្តីណែនាំនេះ និយ័តករទូរគមនាគមន៍កម្ពុជា នឹងសង្ឃឹមថាប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ជ្រាប និងអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះប្រកបដោយសេចក្តីម៉ឺងម៉ាត់ និងប្រសិទ្ធភាពខ្ពស់បំផុត។

ក្នុងករណី ប្រតិបត្តិករទូរគមនាគមន៍ណាមួយ មិនអនុវត្តតាមសេចក្តីណែនាំនេះ នោះប្រតិបត្តិករទូរគមនាគមន៍នោះនឹងប្រឈមជាមួយការទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

ថ្ងៃ ពុធ ៤រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០២០

**ប្រធាន**

**ម៉ុង ចរិយា**

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គស្នងការដ្ឋាននគរបាលជាតិ "ដើម្បីជូនជ្រាប"
- ប្រតិបត្តិករទូរស័ព្ទចល័តទាំងអស់ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ